# ជនជាប់ចោទ ខៀវ សំផន លើកឡើងពីការបាត់បង់ឱកាស
# ដើម្បីតទល់លើឯកសារភ័ស្តុតាង

បកប្រែដោយ ៖ លឹម ជ័យទ័ត្ត

ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣

អាន ហាញខូល

មជ្ឈមណ្ឌលឯកសារកម្ពុជា

នៅក្នុងបណ្តឹងដែលដាក់ជូនអង្គជំនុំជម្រះកាលពីខែកុម្ភៈ ដែលទើបនឹងផ្សព្វផ្សាយជាសាធារណៈកាលពីសប្តាហ៍មុន ជនជាប់ចោទ ខៀវ សំផន បានជំទាស់តវ៉ាអំពីភាពត្រឹមត្រូវ និងភាពមិនលំអៀងរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការអនុវត្តទាក់ទងនឹងឯកសារភ័ស្តុតាងដែលប្រឆាំងនឹងអតីតមេដឹកនាំខ្មែរក្រហមដែលនៅរស់រានមានជីវិតនៅអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី ។ ក្រុមមេធាវីការពារក្តីរបស់ជនជាប់ចោទបានអះអាងថា នីតិវិធី និងគោលបំណង នៃការបើកសវនាការស្តីពីការដាក់បង្ហាញឯកសារគន្លឹះទាំង៣ បានរំលោភលើសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ និងចំពោះមុខក្នុងអំឡុងពេលសវនាការ និងថា ភាគីទាំងអស់នឹងត្រូវការប្រើពេលជាច្រើនបន្ថែមទៀត នៅក្នុងសវនាការសន្និដ្ឋានបិទបញ្ចប់កិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០១ ដើម្បីអាចមានពេលវេលាគ្រប់គ្រាន់ក្នុងការលើកឡើងអំពីឯកសារភ័ស្តុតាងរាប់ពាន់ដែលទទួលយកមកធ្វើជាភ័ស្តុតាង ។

នៅមុនពេលបើកសវនាការលើកដំបូងស្តីពីការបង្ហាញឯកសារគន្លឹះ កាលពីខែកុម្ភៈ ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់អំពីគោលបំណងនៃសវនាការ និងវិសាលភាពនៃសំណើសុំដែលភាគីអាចដាក់ត្រូវអនុញ្ញាតឲ្យដាក់ជូនអង្គជំនុំជម្រះ ៖

> អង្គជំនុំជម្រះមានបំណងផ្តល់ជូនភាគីទាំងអស់នូវឱកាសដើម្បីដាក់បង្ហាញនៅចំពោះមុខអង្គជំនុំជម្រះនូវឯកសារមួយចំនួនដែលត្រូវបានចាត់ទុកថាមានជាប់ទាក់ទងជាពិសេសជាមួយនឹងសវនាការដំណាក់កាលដំបូងនៃសំណុំរឿង០០២/០១ ។ គោលបំណងនៃសវនាការនេះ គឺដើម្បីធានាថាសាធារណជនទូទៅអាចទទួលបានព័ត៌មានទូលំទូលាយស្តីពីឯកសារដែលមាននៅក្នុងសំណុំរឿង និងដើម្បីផ្តល់ឱកាសជូនភាគីទាំងឡាយដែលចង់ធ្វើការកត់សម្គាល់លើឯកសារគន្លឹះទាំងនោះនៅចំពោះមុខអង្គជំនុំជម្រះ ដែលពួកគេចាត់ថាជាឯកសារដែល

មានភាពជាប់ពាក់ព័ន្ធនឹងសំណុំរឿង០០២/០១ ។ នៅពេលណាដែលឯកសារត្រូវបានដាក់បង្ហាញនៅចំពោះមុខអង្គជំនុំជម្រះដោយភាគីនានាក្នុងសវនាការ ជនជាប់ចោទនឹងត្រូវអនុញ្ញាតឲ្យធ្វើអត្ថាធិប្បាយលើឯកសារនោះ ប្រសិនបើជនជាប់ចោទមានបំណងធ្វើដូច្នេះ ។

អង្គជំនុំជម្រះបានពិពណ៌នាសវនាការនោះថា ជាសវនាការផ្សេងពីកិច្ចដំណើរនីតិវិធីនៃការដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះដែលកំពុងតែបន្តធ្វើ និងបានសង្កត់ធ្ងន់ថា "ដោយសារតែសវនាការនេះ ពុំជាប់ទាក់ទងនឹងភាពអាចទទួលយកបាននៃឯកសារដែលបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះ ដូច្នេះភាគីដទៃទៀតពុំត្រូវបានផ្ដល់ពេលវេលាដើម្បីធ្វើការឆ្លើយតបចំពោះការដាក់បង្ហាញឯកសារនេះទេ" ។

ក្រុមមេធាវីការពារក្ដី ខៀវ សំផន ព្រមទាំងភាគីដទៃផ្សេងទៀត បានយល់ដូចគ្នាចំពោះការឆ្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងថា ទោះបីជាជនជាប់ចោទមានសិទ្ធិអាចធ្វើអត្ថាធិប្បាយជាលក្ខណៈបុគ្គលលើឯកសារដែលដាក់បង្ហាញក៏ដោយ ក៏មេធាវីការពារក្ដីរបស់ពួកគាត់ពុំត្រូវបានផ្ដល់ឱកាសឲ្យធ្វើដូច្នេះទេ ។ ក្នុងន័យនេះ សហព្រះរាជអាជ្ញាដែលបានដាក់បង្ហាញឯកសារជាច្រើន នឹងពុំត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ឯកសារនោះដើម្បីចោទប្រកាន់ឡើយ ហើយមេធាវីការពារក្ដីក៏នឹងមិនត្រូវបានអនុញ្ញាតឲ្យធ្វើការឆ្លើយតបចំពោះឯកសារដែលដាក់បង្ហាញដែរ ។

បន្ទាប់ពីមានសវនាការដាក់បង្ហាញឯកសារគន្លឹះលើកដំបូងរួចមក មានឯកសារខ្លះដែលធ្លាប់បានដាក់បង្ហាញដោយសហព្រះរាជអាជ្ញា ត្រូវបានចាត់បញ្ចូលទៅក្នុងប្រភេទឯកសារ E3 ដែលជាប្រភេទឯកសារធ្លាប់ដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដោយមានការជជែកដេញដោលដោយភាគី និងអាចប្រើប្រាស់ជាមូលដ្ឋានក្នុងការវិនិច្ឆ័យដោយអង្គជំនុំជម្រះ ។ ឆ្លើយតបនឹងសំណួរមួយរបស់ ខៀវ សំផន ទាក់ទងនឹងការផ្លាស់ប្ដូរលក្ខន្តិកៈនេះ អង្គជំនុំជម្រះសាលាដំបូងបានបកស្រាយថា ភាគីនានាមានឱកាសក្នុងការជំទាស់ទៅនឹងឯកសារជាក់លាក់ណាមួយ ជាជាងធ្វើការជំទាស់នឹងសវនាការស្ដីពីការដាក់បង្ហាញឯកសារគន្លឹះ ។ ក្រុមមេធាវីការពារក្ដី ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះបានទទួលស្គាល់ថា ឯកសារទាំងនេះពុំត្រូវបានយកមកធ្វើជាកម្មវត្ថុនៃការពិភាក្សាដេញដោលនៅក្នុងសវនាការស្ដីពីការដាក់បង្ហាញឯកសារជាក់លាក់នោះទេ ។

បើយោងតាមក្រុមមេធាវីការពារក្ដី ខៀវ សំផន មុនពេលសវនាការដាក់បង្ហាញឯកសារគន្លឹះលើកទី២ នៅក្នុងខែតុលា ឆ្នាំ២០១២ ក្រុមមេធាវីការពារក្ដី ខៀវ សំផន បានជូនដំណឹងអង្គជំនុំជម្រះថា ខ្លួននឹងពុំចូលរួមនៅក្នុងសវនាការដែលពុំអនុញ្ញាតឲ្យមានការតទល់នៅចំពោះមុខនោះទេ ។ នៅអំឡុងពេលសវនាការ អង្គជំនុំជម្រះសាលាដំបូងបានឆ្លើយតបផ្ទាល់មាត់ចំពោះការជំទាស់របស់ភាគី និងការយល់ច្រឡំចំពោះវិសាលភាពដែលមេធាវីអាចត្រូវបានអនុញ្ញាតឲ្យធ្វើអន្តរាគមន៍ថា នៅចុងបញ្ចប់នៃការ

ធ្វើបទបង្ហាញស្ដីពីឯកសារដោយភាគីនីមួយៗ ភាគីផ្សេងទៀតដែលមានបំណងជំទាស់ អាចធ្វើអត្ថាធិប្បាយបាន។ បន្ទាប់មក ប្រធានអង្គជំនុំជម្រះសាលាដំបូងបានបកស្រាយថា ភាគីនានាអាចធ្វើការកត់សម្គាល់លើឯកសារដែលត្រូវបានដាក់បង្ហាញ ប៉ុន្តែពុំអាចធ្វើការវាយតម្លៃអំពីតម្លៃ ឬទម្ងន់នៃភ័ស្តុតាងបានទេ ដោយសារសវនាការនាពេលនេះ ពុំមែនជាសវនាការសន្និដ្ឋានបិទបញ្ចប់កិច្ចដំណើរការនីតិវិធី។

នៅអំឡុងពេលសវនាការដាក់បង្ហាញឯកសារលើកទីបី នៅក្នុងខែមករា ឆ្នាំ២០១៣ លោកស្រី ចៅក្រម ខាតព្រ៉ាយត៍ គូសបញ្ជាក់ថា ៖

> នៅខណៈដែលពុំមានការពិភាក្សាពេញលេញណាមួយអំពីភាពអាចទទួលយកបាននៃឯកសារដែលបានបង្ហាញនាដំណាក់កាលនេះត្រូវបានអនុញ្ញាតដោយអង្គជំនុំជម្រះ លើកលែងតែបញ្ហាដែលពាក់ព័ន្ធនឹងភាពអាចទទួលយកបានពុំត្រូវបានពិភាក្សាពេញលេញ ឬសម្រេចពីពេលមុន។ ដូច្នេះវាច្បាស់ណាស់ថា អង្គជំនុំជម្រះពុំដែលបានរារាំងជនជាប់ចោទ ឬមេធាវីការពារក្ដីរបស់ពួកគេ ក្នុងការពិភាក្សាអំពីភាពសមស្រប ឬអំពីតម្លៃជាភ័ស្តុតាងនៃឯកសារឡើយ។

នៅចុងក្រោយ នៅក្នុងអំឡុងពេលនៃកិច្ចប្រជុំរៀបចំសវនាការកាលពីសប្ដាហ៍មុន ចៅក្រម ខាតព្រ៉ាយត៍ បានបកស្រាយមកវិញថា សវនាការស្ដីពីការដាក់បង្ហាញឯកសារគន្លឹះ គឺជាឱកាសមួយដែលផ្ដល់ជូនភាគីនីមួយៗដើម្បីដាក់បង្ហាញឯកសារ ហើយភាគីដទៃផ្សេងទៀតអាចធ្វើអត្ថាធិប្បាយលើចំណុចផ្សេងៗ លើកលែងតែភាពអាចទទួលយកបាននៃឯកសារនោះ ដែលបានអង្គជំនុំជម្រះធ្លាប់បានសម្រេចរួចហើយ។

ក្រុមមេធាវីការពារក្ដី ខៀវ សំផន បានលើកឡើងថា វិធានដែលយកមកគ្រប់គ្រងលើកិច្ចដំណើរការនីតិវិធីដាក់បង្ហាញឯកសារ នៅមានលក្ខណៈពុំច្បាស់លាស់ និងផ្លាស់ប្ដូរនៅស្របពេលដែលកំពុងមានសវនាការជំនុំជម្រះសេចក្ដី។ មេធាវីបានលើកឡើងបន្ថែមទៀតថា តម្លៃជាភ័ស្តុតាងនៃឯកសារ អាចត្រូវបានវាយតម្លៃតែនៅក្នុងអំឡុងពេលនៃការបិទបញ្ចប់សវនាការតែប៉ុណ្ណោះ ហើយសវនាការស្ដីពីការដាក់បង្ហាញភ័ស្តុតាង មិនអាចយកមកផ្លាស់ប្ដូរជាមួយនឹងឱកាសនោះបានទេ ៖

> នៅក្រោយពេលដែលមានការបង្ហាញឯកសារភ័ស្តុតាងទាំងមូល ទើបភាគីអាចមានលទ្ធភាពធ្វើការវិភាគទៅលើឯកសារទាំងនោះ ធ្វើការតតាំងឯកសារទាំងនោះទៅនឹងសក្ខីកម្មព្រមទាំងឯកសារដទៃទៀតដែលបានបង្ហាញចំពោះអង្គជំនុំជម្រះ មុនពេលធ្វើសេចក្ដីសន្និដ្ឋាននានាដែលជាជំនួយដល់អង្គជំនុំជម្រះក្នុងការសម្រេចសេចក្ដីរបស់ខ្លួន។

ហេតុផលនេះ បានធ្វើឲ្យក្រុមមេធាវីការពារក្តីជំទាស់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលកំណត់ចំនួនទំព័រនៃសារណាសន្និដ្ឋានចុងក្រោយរបស់ភាគីត្រឹម១០០ទំព័រ និងថា ការធ្វើដូច្នេះនឹងរំលោភលើសិទ្ធិរបស់ជនជាប់ចោទដើម្បីដេញដោលអំពីតម្លៃនៃភស្តុតាងទាំងអស់ រួមទាំងការដាក់បង្ហាញឯកសារនៅអំឡុងពេលនៃសវនាការបង្ហាញឯកសារគន្លឹះផង។ ក្រុមមេធាវីបានស្នើសុំកុំឲ្យមានសវនាការដាក់បង្ហាញឯកសារគន្លឹះបន្ថែមទៀត និងថា ត្រូវតែមានការធានាថា មេធាវីការពារក្តីទទួលបាននូវឱកាសពិតប្រាកដ ក្នុងការពិភាក្សាដេញដោលលើឯកសារចំនួនរាប់ពាន់ដែលត្រូវបានទទួលយកធ្វើជាភស្តុតាង ហើយការពិភាក្សាដេញដោលនេះត្រូវធ្វើនៅក្នុងពេលដែលមានសេចក្តីសន្និដ្ឋានបញ្ចប់ ដោយអនុញ្ញាតឲ្យ ខៀវ សំផន (ប្រសិនបើគាត់មានបំណង) អាចធ្វើអត្ថាធិប្បាយលើរាល់ឯកសារគន្លឹះដែលត្រូវបានដាក់បង្ហាញ។ មេធាវីក៏បានស្នើសុំអង្គជំនុំជម្រះនូវចំនួនទំព័របន្ថែមសម្រាប់សារណាសន្និដ្ឋានចុងក្រោយ និងផ្តល់នូវពេលវេលាគ្រប់គ្រាន់សម្រាប់លើកឡើងនូវទឡ្ហីករណ៍ និងការដាក់សំណើសុំរបស់ខ្លួន។

ពុំទាន់មានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះលើសំណើសុំនេះនៅឡើយទេ។ ប៉ុន្តែទោះបីជាយ៉ាងណា កាលពីសប្តាហ៍មុន អង្គជំនុំជម្រះបានគ្រោងនឹងបើកសវនាការស្តីពីការដាក់បង្ហាញឯកសារគន្លឹះចុងក្រោយបង្អស់ និងបានលើកឡើងថា អង្គជំនុំជម្រះនឹងមិនសម្រេចលើសំណើសុំទាំងឡាយ ដើម្បីទទួលបានចំនួនទំព័របន្ថែមក្នុងសារណាសន្និដ្ឋានចុងក្រោយទេ។